**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ១៩៣៩ ឧសក.គក..សជណ

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបមកលោក-លោកស្រីម្ចាស់រោងចក្រ សហគ្រាសទាំងអស់ជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្មចាំបាច់ត្រូវការចុះធ្វើបច្ចុប្បន្នភាពស្ថិតិរោងចក្រទាំងអស់ដើម្បីធ្វើការវាយតម្លៃភាពរីកចម្រើនលើវិស័យឧស្សាហកម្ម សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ក្នុងជំពូកទី ២ ការបង្កើត និងកិច្ចដំណើរការ មាត្រា ១៩ បានចែងថា ម្ចាស់រោងចក្រត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ចាំបាច់នានាតាមការកំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្នុងជំពូកទី ៦ ទោសប្បញ្ញត្តិ មាត្រា ៤៧ បានចែងថា ជនណាដែលមិនផ្តល់ ឬផ្តល់របាយការណ៍មិនពិត ឬប្រព្រឹត្តល្មើសនឹងមាត្រា ១៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១០.០០០.០០០ រៀល (ដប់លានរៀល) ទៅ ៥០.០០០.០០០ (ហាសិបលានរៀល) និងផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សង្ឃឹមយ៉ាងមុតមាំថា អស់លោក-លោកស្រីដែលជាម្ចាស់រោងចក្រ សហគ្រាសទាំងអស់នឹងជួយសហការជាមួយមន្ត្រីរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការចុះធ្វើបច្ចុប្បន្នភាពស្ថិតិរោងចក្រ និងផ្តល់របាយការណ៍ផលិតកម្មប្រចាំខែ មកនាយកដ្ឋានកិច្ចការឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានរៀងរាល់ខែ មុនថ្ងៃទី ១០ នៃខែបន្ទាប់ (ដូចមានតារាងគំរូជូនភ្ជាប់មកជាមួយ) ។ ទិន្នន័យ និងរបាយការណ៍ដែលបានផ្តល់មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងត្រូវបានធានារក្សាទុកជាការសម្ងាត់វិជ្ជាជីវៈរបស់ក្រសួង និងមិនត្រូវបានយកទៅផ្សព្វផ្សាយជាសាធារណៈឡើយ បើគ្មានការយល់ព្រមពីម្ចាស់រោងចក្រ សហគ្រាសសាមី ។ បើពុំដូច្នោះទេ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងចុះអនុវត្តតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជាចាំបាច់ ។

សូមអស់លោក-លោកស្រីម្ចាស់រោងចក្រ សហគ្រាសទាំងអស់ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

ទូរស័ព្ទទំនាក់ទំនង: ០១១ ៩៧០ ៧៦០
Email: hokthyne@gmail.com
hortpheng@yahoo.com